**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ០៤៩......សហវ

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១

# សេចក្តីជូនដំណឹង

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រីដែលជាម្ចាស់អចលនទ្រព្យធំៗនិង/ឬនៅច្រើនកន្លែងក្នុងរាជធានីភ្នំពេញ ដែលត្រូវជាប់ពន្ធលើអចលនទ្រព្យមេត្តាជ្រាបថា ការបង់ពន្ធលើអចលនទ្រព្យនឹងត្រូវបញ្ចប់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ខាងមុខនេះ។ គិតមកទល់ពេលនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្កេតឃើញថា ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រីមួយចំនួនដែលមានអចលនទ្រព្យធំៗនិង/ឬនៅច្រើនកន្លែងក្នុងរាជធានីភ្នំពេញ បានបំពេញកាតព្វកិច្ចចុះបញ្ជីនិងបង់ពន្ធលើអចលនទ្រព្យនេះរួចរាល់ហើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមសំដែងមូលវិចារណ៍ថ្លៃថ្លាចំពោះការបំពេញកាតព្វកិច្ចពន្ធដារនេះរបស់ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ទាំងនេះ។ ដោយឡែក ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ដែលជាម្ចាស់អចលនទ្រព្យធំៗនិង/ឬនៅច្រើនកន្លែង មួយចំនួនទៀត នៅអល់អែកមិនទាន់ចុះបញ្ជីនិងបង់ពន្ធនៅឡើយ ទោះបីជាមានការរំលឹកជាច្រើនដងមកហើយក្តី។

ជាថ្មីម្តងទៀត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមអញ្ជើញឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ដែលជាម្ចាស់អចលនទ្រព្យដែលត្រូវជាប់ពន្ធទាំងអស់ ពិសេសអចលនទ្រព្យធំៗនិង/ឬនៅច្រើនកន្លែងក្នុងរាជធានីភ្នំពេញ មកចុះបញ្ជីនិងបង់ពន្ធឲ្យទាន់ពេលវេលា ត្បិតកាលបរិច្ឆេទផុតកំណត់នៅសល់ប្រមាណ ១ខែ ទៀតប៉ុណ្ណោះ។ ការមិនបានចុះបញ្ជីនិងបង់ពន្ធលើអចលនទ្រព្យឲ្យបានទាន់ពេលវេលា នឹងត្រូវទទួលរងទោសទណ្ឌ ដែលរួមមាន ប្រាក់ពន្ធបន្ថែមនិងការប្រាក់ និងទោសទណ្ឌផ្នែករដ្ឋបាលផ្សេងទៀត។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ដែលជាកម្មវត្ថុនៃសេចក្តីជូនដំណឹងនេះ រួសរាន់អញ្ជើញទៅទាក់ទងនឹងសាខាពន្ធដារខណ្ឌដែលអចលនទ្រព្យតាំងនៅ ដើម្បីបំពេញបែបបទបង់ប្រាក់ពន្ធលើអចលនទ្រព្យឲ្យបានទាន់ពេលវេលា។

ប្រសិនបើមានចម្ងល់ផ្សេងៗ ទាក់ទិននឹងការបំពេញទម្រង់ ការវាស់វែងអចលនទ្រព្យ ឬការគណនាប្រាក់ពន្ធ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រីប្រភេទនេះអាចទំនាក់ទំនងតាមទូរស័ព្ទ ឬផ្ញើសារមកលេខ៖

- សាខាពន្ធដារខណ្ឌដូនពេញ ទូរស័ព្ទលេខ : ០១២ ៨៥០ ៩៧៧
- សាខាពន្ធដារខណ្ឌ៧មករា ទូរស័ព្ទលេខ : ០១២ ៥៩០ ០០៥
- សាខាពន្ធដារខណ្ឌចំការមន ទូរស័ព្ទលេខ : ០៧៧ ៩៩៩ ៩២៣
- សាខាពន្ធដារខណ្ឌទួលគោក ទូរស័ព្ទលេខ : ០១២ ៦២១ ៨៨៥
- សាខាពន្ធដារខណ្ឌមានជ័យ ទូរស័ព្ទលេខ : ០១២ ៨១២ ៥៦៧
- សាខាពន្ធដារខណ្ឌឫស្សីកែវ-សែនសុខ ទូរស័ព្ទលេខ : ០១១ ៧៧៧ ១៧៥
- សាខាពន្ធដារខណ្ឌដង្កោ ទូរស័ព្ទលេខ : ០១២ ៨២៩ ២៤៨

ក្នុងករណីចាំបាច់ អគ្គនាយកដ្ឋានពន្ធដារអាចនឹងបញ្ជូនមន្ត្រីជំនាញចុះផ្ទាល់ទៅជួយបន្ថែមទៀត។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសង្ឃឹមជឿជាក់លើស្មារតីគោរពប្រតិបត្តិច្បាប់របស់ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ដែលជាម្ចាស់អចលនទ្រព្យ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ